**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

នាយកដ្ឋានព័ត៌មាន និងឯកសារ

# សេចក្តីជូនព័ត៌មាន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំគណៈប្រតិភូជាន់ខ្ពស់អញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១១ "The 11th ASEM Summit " ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី ១៥ ដល់ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៦ នៅទីក្រុងអ៊ូឡង់បាទ័រ ប្រទេសម៉ុងហ្គោលី តបតាមការអញ្ជើញរបស់ឯកឧត្តម ត្សាឃីអាហ្គីន អែលបេហ្គឌ្ឋ្រ (Tsakhiagiin Elbegdorj) ប្រធានាធិបតីម៉ុងហ្គោលី ។

គណៈប្រតិភូអមដំណើររួមមាន ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងសមាជិករាជរដ្ឋាភិបាលកម្ពុជាដទៃទៀត។

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នឹងថ្លែងសុន្ទរកថានៅក្នុងសម័យប្រជុំពេញអង្គរបស់កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើប្រធានបទ " ការតភ្ជាប់ផ្នែកទន់ " ។

ក្រោមប្រធានបទ " រយៈពេល២០ឆ្នាំនៃកិច្ចប្រជុំអាស៊ី - អឺរ៉ុប ៖ ភាពជាដៃគូសម្រាប់អនាគតតាមរយៈការតភ្ជាប់ "កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១១ នឹងពិភាក្សាលើបញ្ហាសំខាន់ៗជាច្រើន រួមមាន ការវាយតម្លៃលើបទពិសោធន៍របស់ ASEM ក្នុងរយៈពេល២០ឆ្នាំកន្លងមក ការកសាងការតភ្ជាប់ផ្នែករឹង និងទន់រវាងអាស៊ី-អឺរ៉ុប ទិសដៅអនាគតរបស់ ASEM បំរែបំរួលអាកាសធាតុ ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនិងប្រព័ន្ធពហុពាណិជ្ជកម្ម ការកាត់បន្ថយ និងការគ្រប់គ្រងហានិភ័យគ្រោះធម្មជាតិ សន្តិសុខថាមពល សន្តិសុខស្បៀង ការគ្រប់គ្រងទឹក ព្រមទាំងបញ្ហាតំបន់ និងអន្តរជាតិ ។

កិច្ចប្រជុំកំពូល គ្រោងនឹងអនុម័តលើឯកសារស្តីពីលទ្ធផលកិច្ចប្រជុំសំខាន់ពីរគឺ៖ សេចក្តីប្រកាសអ៊ូឡង់បាទ័រ (The Ulaanbaatar Declaration) និងសេចក្តីថ្លែងការណ៍របស់ប្រធានអង្គប្រជុំ (The Chair's Statement)។

ក្រៅពីកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នឹងជួបទ្វេភាគីជាមួយឯកឧត្តម **លី ខឺឈាង** (Li Keqiang) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន ឯកឧត្តម **ស៊ីន ហ្សូអាបេ** (Shinzo Abe) នាយករដ្ឋមន្ត្រីជប៉ុន និងលោកជំទាវ ប៉ាក គឿនហេ (Park Geun-hye) ប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ ។/.

ភ្នំពេញ, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦